## ទម្រង់ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំ 2010 ដែលបានតម្រូវអោយមានសម្រាប់អ្នកទាមទារសំណង ទៅលើរាល់ការបាត់បង់ប្រាក់ចំណូលទាំងអស់។

ថ្ងៃទី15 ខែសីហា ឆ្នាំ2011 ស្ថាប័ន GCCF បានយល់ព្រមទទួលយកកំណែទម្រង់ទៅលើជម្រើសក្នុងការទូទាត់ប្រាក់សំណងក្នុងការគ្រប់គ្រងគោលការណ៍ច្បាប់ចុងក្រោយ សិទ្ធិទទួលបានការទូទាត់ និងលក្ខខណ្ឌភស្តុតាងដែលបានចង្អុលបង្ហាញ និងវិធីសាស្ត្រក្នុងការទូទាត់ប្រាក់សំណងចុងក្រោយ។ តាមរយៈកំណែទម្រង់នោះ ការបាត់បង់ទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងប្រាក់ចំណូលដែលរកបានមានចំនួនតិចជាងអត្រាកំនើន 5% ខ្ពស់ជាងកម្រិតកាលពីឆ្នាំ2010 ត្រូវបានគេសន្មតថាមកពីកត្តាពាក់ព័ន្ធផ្សេងៗក្រៅពីការហៀប្រេង និងមិនត្រូវបានគេទូទាត់សងការខូចខាតត្រលប់មកវិញឡើយ។ គោលនយោបាយនេះអនុវត្តចំពោះអ្នកទាមទារសំណងបុគ្គលក្រោយថ្ងៃទី30 ខែមិថុនា ឆ្នាំ2011 និងអ្នកទាមទារសំណងអាជីវកម្មក្រោយថ្ងៃទី31 ខែមិនា ឆ្នាំ2011។ ដើម្បីអាចអនុវត្តគោលនយោបាយនេះអោយបានត្រឹមត្រូវ និងមានលក្ខណៈដូចគ្នាចំពោះអ្នកទាមទារសំណងទាំងអស់ ស្ថាប័ន GCCF ត្រូវតែមានឯកសារដែលបង្ហាញពីប្រាក់ចំណូលរកបានសរុបរបស់អ្នកទាមទារសំណងសម្រាប់ឆ្នាំ 2010។ ដូច្នេះ អ្នកទាមទារសំណងបុគ្គល ឬអាជីវកម្មដែលស្វែងរកការទូទាត់សំណងសម្រាប់ការខាតបង់ប្រាក់ចំណូលដែលរកបាននៅក្នុងកំឡុងពេលណាមួយនៃឆ្នាំ2011 ដែលងាយស្ថិតនៅក្រោមគោលនយោបាយនេះ ត្រូវតែផ្ញើច្បាប់ចម្លងនៃទម្រង់ពន្ធសហព័ន្ធពេលលេញដែលត្រូវបង់របស់ខ្លួនសម្រាប់ឆ្នាំ 2010 ក្នុងនោះរួមមានរាល់ទម្រង់ពាក្យ កាលវិភាគ ឯកសារភ្ជាប់ទាំងឡាយណា ដែលបានបំពេញមកជាមួយនិងទម្រង់ពន្ធនោះ។

ដើម្បីទទួលបានការពេញចិត្តចំពោះឯកសារនេះ
អ្នកទាមទារសំណងបុគ្គលដែលស្វែងរកការទូទាត់សងត្រលប់មកវិញសម្រាប់ការខាតបង់ប្រាក់ចំណូលដែលរកបានក្នុងកំឡុងពេលណាមួយក្រោយថ្ងៃទី30 មិថុនា ឆ្នាំ2011 ត្រូវតែផ្ញើច្បាប់ចម្លងនៃទម្រង់1040 ទម្រង់ 1040EZ ឬទម្រង់ 1040A ដែលបំពេញជាមួយសេវកម្ម IRS សម្រាប់ឆ្នាំ 2010 ក្នុងនោះរួមមានទម្រង់ កាលវិភាគ និងឯកសារភ្ជាប់ ដែលបានបំពេញជាមួយទម្រង់ពន្ធដែលត្រូវបង់ និងរាល់ការកែតម្រូវណាមួយនៅក្នុងទម្រង់ពន្ធដែលត្រូវបង់ ដែលអ្នកទាមទារសំនងបានបំពេញមកជាមួយសេវាកម្ម IRS។ ច្បាប់ចម្លងមិនតម្រូវអោយចុះហត្ថលេខា ប៉ុន្តែត្រូវតែពិតប្រាកដ ត្រឹមត្រូវ និងជាច្បាប់ចម្លងនៃទម្រង់ពន្ធពេញលេញ ដូចដែលបានបំពេញមកជាមួយសេវាកម្ម IRS។ ប្រសិនបើ អ្នកទាមទារសំណង និងប្តី ឬប្រពន្ធរបស់អ្នកទាមទារសំណងបានបំពេញរួមគ្នានៅលើទម្រង់ពន្ធដែលត្រូវបង់នោះ ស្ថាប័ន GCCF ត្រូវតែអាចកំនត់ពីប្រាក់ចំណូលមួយណាក្នុងចំណោមប្រាក់ចំណូល ដូចដែលបានរាយការណ៍នៅក្នុងទម្រង់ពន្ធដែលត្រូវបង់នោះត្រូវបានរកបានដោយអ្នកទាមទារសំណង និងដែលត្រូវបានរកបានដោយប្តី ឬប្រពន្ធ។ ធម្មតាទម្រង់ពាក្យ W-2, 1099 របស់ប្តី ឬប្រពន្ធ ឬទម្រង់ដាច់ដោយឡែកណាផ្សេងទៀត ដែលបានបំពេញជាមួយនឹងទម្រង់ពន្ធដែលត្រូវបង់នឹងអនុញ្ញាតសិទ្ធិអោយស្ថាប័ន GCCF ធ្វើការកត់ចំណាំនូវប្រាក់ចំណូលរបស់ប្តី ឬប្រពន្ធពីប្រាក់ចំណូលរួមរបស់អ្នកទាមទារសំណងនេះ។ ប្រសិនបើអ្នកទាមទារសំណងមិនអាចទទួលបានច្បាប់ចម្លងនៃទម្រង់ពន្ធដែលត្រូវបង់របស់លោក ឬលោកស្រីនៅឆ្នាំ 2010ទេ សេវាកម្ម IRS អាចផ្តល់ជូនច្បាប់ចម្លងនៃទម្រង់ពន្ធដែលមានការប្រែសំរួល ដើម្បីបង្ហាញពីរាល់ព័ត៌មានទាំងឡាយណាដែលមាននៅក្នុងទម្រង់ពន្ធនោះ។ ស្ថាប័ន GCCF នឹងទទួលយកច្បាប់ចម្លងនៃទម្រង់ពន្ធដែលមានការប្រែសំរួលនេះ

ប្រសិនបើច្បាប់ចម្លងនៃទម្រង់ពន្ធពិតប្រាកដរបស់អ្នកទាមទារសំណងមិនអាចប្រើការបាន។

អ្នកទាមទារសំណងអាជីវកម្ម ដែលស្វែងរកការសងសំណងត្រលប់មកវិញសម្រាប់ការខាតបង់ផលចំណេញក្នុងកំឡុងពេលណាមួយក្រោយថ្ងៃទី31 ខែមិនា ឆ្នាំ2011 ត្រូវតែផ្ញើច្បាប់ចម្លងនៃទម្រង់បង់ពន្ធរបស់ពួកគេសម្រាប់ឆ្នាំ2010 នោះមក។ គណនេយ្យនៃស្ថាប័ន GCCF នឹងទាក់ទងមកអ្នកទាមទារសំណងអាជីវកម្មពីរឿងផ្ញើឯកសារសមស្របដែលអនុលោមទៅតាមតម្រូវការនេះ។